ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៤៧ សរាចរ

# សារាចរណែនាំ
## ស្តីពី
## ការគ្រប់គ្រងរថយន្តនាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ និងការកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

នាពេលកន្លងមក រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រសួង-ស្ថាប័នរដ្ឋ និងបុគ្គលពាក់ព័ន្ធនាំចូលរថយន្តសម្រាប់បម្រើការងារ ដែលជាប្រភេទទំនិញមានវេទយិតភាពខ្ពស់ រួមចំណែកយ៉ាងសំខាន់ក្នុងចំណូលពន្ធ និងអាករគយដែលជាប្រភពចំណូលដ៏ចំបងនៃថវិកាជាតិ ដោយដាក់ពន្ធអាករជាបន្ទុករបស់រដ្ឋ ប៉ុន្តែមានករណីខ្លះការប្រើប្រាស់រថយន្តទាំងនោះមិនទាន់ចំគោលដៅ និងធានាបាននូវប្រសិទ្ធភាពពេញលេញ រីឯការកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋក៏មិនទាន់បានសព្វគ្រប់អស់នៅឡើយ។

អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨, ច្បាប់ស្តីពីគយ ឆ្នាំ២០០៧, ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ និងវិសោធនកម្មច្បាប់ជាបន្តបន្ទាប់, សារាចរលេខ ០៧.សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល និងក្នុងគោលដៅពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងរថយន្តគ្រប់ប្រភេទរបស់ក្រសួង-ស្ថាប័នរដ្ឋ និងបុគ្គលពាក់ព័ន្ធដែលបានអនុញ្ញាតឱ្យនាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ រាជរដ្ឋាភិបាលសូមធ្វើការណែនាំ និងដាក់វិធានការឱ្យអនុវត្តដូចខាងក្រោម៖

### ១. អំពីពន្ធនិងអាករនាំចូល

- ការនាំចូលរថយន្តរបស់ក្រសួង-ស្ថាប័នរដ្ឋ និងបុគ្គលពាក់ព័ន្ធ ដែលអាចទទួលបានការបង់ពន្ធអាករជាបន្ទុករបស់រដ្ឋ ត្រូវសុំការអនុញ្ញាតយល់ព្រមជាមុនពីរាជរដ្ឋាភិបាល។ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ឱ្យនាំចូលរថយន្ត ដោយពន្ធអាករជាបន្ទុករបស់រដ្ឋ រថយន្តទាំងនោះត្រូវបំពេញបែបបទនាំចូលដោយស្របច្បាប់

- ការនាំចូលរថយន្តរបស់អង្គទូត អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ជាមធ្យោបាយចាំបាច់បំពេញការងារត្រូវអនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិ, កិច្ចព្រមព្រៀងក្របខ័ណ្ឌរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃប្រទេសដៃគូអភិវឌ្ឍន៍ ឬអង្គការអន្តរជាតិ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវបន្តពង្រឹងយន្តការគ្រប់គ្រងលើរថយន្តដែលទទួលបានគោលការណ៍ពន្ធអាករជាបន្ទុករបស់រដ្ឋ តាមរយៈការបិទលតាប័ត្រ (Vignette) ដោយឡែក
- **ការធ្វើអំណោយជារថយន្តពីប្រភពក្នុងនិងក្រៅប្រទេស** ជូនក្រសួង-ស្ថាប័នរដ្ឋអាចធ្វើទៅបាន លុះត្រាតែរថយន្តទាំងនោះត្រូវបាននាំចូលដោយស្របច្បាប់ និងបានបំពេញកាតព្វកិច្ចពន្ធអាករតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន លើកលែងតែមានការអនុញ្ញាតដោយឡែកពីរាជរដ្ឋាភិបាល។

### ២. អំពីការចុះបញ្ជីរថយន្តជាទ្រព្យសម្បត្តិរដ្ឋ

- គ្រប់ក្រសួង-ស្ថាប័នរដ្ឋដែលទិញ និងនាំចូលរថយន្តដោយបង់ពន្ធអាករតាមច្បាប់ជាធរមានត្រូវកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- គ្រប់ក្រសួង-ស្ថាប័នរដ្ឋ និងបុគ្គលពាក់ព័ន្ធដែលទទួលបានការអនុញ្ញាតឱ្យនាំចូលរថយន្តដោយស្របច្បាប់ ដោយពន្ធអាករជាបន្ទុករបស់រដ្ឋត្រូវកត់ត្រារថយន្តទាំងនោះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ លើកលែងតែករណីមន្ត្រីជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ត្រឡប់មកពីបំពេញបេសកកម្មរយៈពេលវែងនៅក្រៅប្រទេស ដែលត្រូវបានកំណត់ក្នុងបទប្បញ្ញត្តិដោយឡែករួចហើយ
- បញ្ជីសារពើភណ្ឌត្រូវបញ្ជូន ១ច្បាប់ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ)។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំយន្តការចែករំលែកព័ត៌មានរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដើម្បីពង្រឹងការគ្រប់គ្រងរថយន្តស្ថិតក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ការចុះបញ្ជីផ្តល់ប័ណ្ណសំគាល់រថយន្ត និងផ្លាកលេខសម្គាល់រថយន្តដែលជាទ្រព្យសម្បត្តិរដ្ឋ ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធអាចធ្វើទៅបាន លុះត្រាតែរថយន្តទាំងនោះត្រូវបាននាំចូលដោយស្របច្បាប់ និងបានបំពេញកាតព្វកិច្ចពន្ធអាករតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

### ៣. អំពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

- រថយន្តដែលជាទ្រព្យសម្បត្តិរដ្ឋនឹងត្រូវបានអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទបាន លុះត្រាតែរថយន្តនោះត្រូវបាននាំចូលដោយស្របច្បាប់ និងបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

- រថយន្តដែលកត់ត្រាចូលបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបំពេញកាតព្វកិច្ចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- រថយន្តដែលកត់ត្រាចូលបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ អាចទទួលបានការអនុញ្ញាតលើកលែងពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំបាន លុះត្រាតែរថយន្តនោះមានលក្ខណៈសម្បត្តិស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**៤. អំពីការទិញរថយន្តដោយប្រើប្រាស់ថវិការដ្ឋ**

- ការទិញរថយន្តដោយប្រើប្រាស់ថវិការដ្ឋ ដើម្បីជាមធ្យោបាយចាំបាច់បំពេញការងាររដ្ឋ ត្រូវសុំការអនុញ្ញាតជាគោលការណ៍ជាមុនពីរាជរដ្ឋាភិបាល និងត្រូវមានគ្រោងក្នុងឥណទានថវិកាប្រចាំឆ្នាំ
- ចាប់ពីឆ្នាំ២០១៧ តទៅ សំណើសុំទិញរថយន្តដោយប្រើប្រាស់ថវិការដ្ឋរបស់ក្រសួង-ស្ថាប័ន ត្រូវរួមបញ្ចូលឱ្យហើយនូវពន្ធនិងអាករគ្រប់ប្រភេទ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន សាលារាជធានី-ខេត្ត និងនីតិបុគ្គលសាធារណៈដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ*
*-គ្រប់សាលារាជធានី ខេត្ត*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*